# ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
លេខ : ០៩៨/២៦ ក.ប/ប្រ.ក.វ.ក

## ប្រកាស
## ស្តីពី
## ក្រុមប្រឹក្សាអាជ្ញាកណ្តាល
## រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥១៦/០០៧ ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហជីព
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១២០/០០១ ចុះថ្ងៃទី០៣ ខែមករា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្ម មាត្រា៣ មាត្រា១៧ មាត្រា២០ មាត្រា២១ មាត្រា២៧ មាត្រា២៨ មាត្រា២៩ មាត្រា៥៤ មាត្រា៥៥ និងមាត្រា៥៩ នៃច្បាប់ស្តីពីសហជីព ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥១៦/០០៧ ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៦



អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨៤៣៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩

- បានឃើញព្រះរាជក្រមលេខ នស/រកម/១០២១/០១១ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា១២៣ មាត្រា១៣៨ មាត្រា១៦២ មាត្រា៣០០ មាត្រា៣៤៣ មាត្រា៣៥០ មាត្រា៣៦៣ និងមាត្រា៣៦៧ នៃច្បាប់ស្តីពីការងារ ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧
- បានឃើញអនុក្រឹត្យលេខ២៣៦ អនក្រ.បក ចុះថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០២៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញប្រកាសលេខ០៧៣/២៥ ក.ប/ប្រ.ក.វ.ក ចុះថ្ងៃទី៤ ខែមីនា ឆ្នាំ២០២៥ ស្តីពីនីតិវិធីនៃការដោះស្រាយវិវាទបុគ្គល
- បានឃើញប្រកាសលេខ០៧៤/២៥ ក.ប/ប្រ.ក.វ.ក ចុះថ្ងៃទី៤ ខែមីនា ឆ្នាំ២០២៥ ស្តីពីនីតិវិធីនៃការដោះស្រាយវិវាទការងាររួម
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ

## សម្រេច

## ជំពូកទី ១
## សមាសភាព និងទីស្នាក់ការក្រុមប្រឹក្សាអាជ្ញាកណ្តាល

**ប្រការ១ .-**

ក្រុមប្រឹក្សាអាជ្ញាកណ្តាលត្រូវមានសមាជិកយ៉ាងតិច ៣០(សាមសិប)រូប។

រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវចេញប្រកាសតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលជារៀងរាល់ឆ្នាំយ៉ាងតិច ១៤(ដប់បួន)ថ្ងៃ នៃថ្ងៃធ្វើការ មុនចប់អាណត្តិ។

**ប្រការ២ .-**

សមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលមានអាណត្តិ ១(មួយ)ឆ្នាំ និងត្រូវបានតែងតាំងសាជាថ្មីជារៀងរាល់ឆ្នាំ ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ លើកលែងតែៈ

ក-សមាជិកនោះទទួលមរណភាព លាលែងពីតំណែង ឬក្លាយជាជនអសមត្ថភាពមិនអាចបំពេញភារកិច្ចជាអាជ្ញាកណ្តាល។

ខ-សមាជិកនោះបាត់បង់គុណវុឌ្ឍិជាអាជ្ញាកណ្តាល ស្របតាមប្រការ៤ នៃប្រកាសនេះ។

ទោះបីអាណត្តិរបស់សមាជិកណាម្នាក់បានចប់ហើយក៏ដោយ ក៏សមាជិករូបនោះត្រូវបន្តការងាររបស់ខ្លួននៅក្នុងក្រុមអាជ្ញាកណ្តាលដែលខ្លួនត្រូវបានជ្រើសរើសឱ្យចូលកាលពីមុនពេលផុតអាណត្តិរបស់ខ្លួន រហូតដល់សេចក្តីបង្គាប់អាជ្ញាកណ្តាលត្រូវបានធ្វើឡើង ឬដំណើរការសម្រេចសេចក្តីនៃអាជ្ញាកណ្តាលត្រូវបានបញ្ឈប់។

**ប្រការ៣ .-**

សមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលមានសមាសភាពដូចតទៅៈ

ក-១/៣ (មួយភាគបី) ស្នើឡើងដោយក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។

ខ-១/៣ (មួយភាគបី) ស្នើឡើងដោយអង្គការវិជ្ជាជីវៈរបស់និយោជក ដែលជាសមាជិកពេញសិទ្ធិនៃគណៈកម្មការប្រឹក្សាការងារ។

គ- ១/៣ (មួយភាគបី) ស្នើឡើងដោយអង្គការវិជ្ជាជីវៈរបស់កម្មករនិយោជិត ដែលជាសមាជិកពេញសិទ្ធិនៃគណៈកម្មការប្រឹក្សាការងារ។

សមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលត្រូវបានតែងតាំងឡើងដោយផ្អែកតាមសំណើឈ្មោះខាងលើ។

សមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលណាម្នាក់ ដែលបានបាត់បង់តួនាទីរបស់ខ្លួន នឹងត្រូវជំនួសដោយសមាជិកថ្មីសម្រាប់រយៈពេលដែលនៅសល់ក្នុងអាណត្តិនោះ ស្របតាមនីតិវិធីស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាល ដូចមានចែងក្នុងប្រកាសនេះ។

**ប្រការ៤ .-**

ដើម្បីក្លាយជាអាជ្ញាកណ្តាល ត្រូវមានគុណវុឌ្ឍិដូចខាងក្រោម៖

ក- មានអាយុយ៉ាងតិច ២៨(ម្ភៃប្រាំបី)ឆ្នាំ

ខ- មានបទពិសោធការងារយ៉ាងតិច ៥(ប្រាំ)ឆ្នាំ ពាក់ព័ន្ធវិស័យច្បាប់ និង/ឬមានបទពិសោធយ៉ាងតិច ២(ពីរ)ឆ្នាំ ក្នុងវិស័យការងារ ឬការដោះស្រាយវិវាទការងារ

គ- មានសញ្ញាបត្របរិញ្ញាបត្រនីតិសាស្ត្រ ឬសញ្ញាបត្រសមមូលឡើងទៅ

ឃ- មានសញ្ញាបត្រ ឬវិញ្ញាបនបត្រ ស្តីពីអាជ្ញាកណ្តាល ចេញដោយវិទ្យាស្ថានជាតិការងារនៃក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ

ង- មិនមែនជាមន្ត្រីរាជការស៊ីវិល ឬមន្ត្រីនគរបាលជាតិ ឬយោធិន

ច- មិនមែនជាម្ចាស់ ឬនាយកសហគ្រាស ក្រុមហ៊ុន រោងចក្រ ឬថ្នាក់ដឹកនាំគ្រប់គ្រង និងអ្នកទទួលខុសត្រូវកិច្ចការរដ្ឋបាលរបស់អង្គការវិជ្ជាជីវៈ ក្នុងរយៈពេល ២(ពីរ)ឆ្នាំ ចុងក្រោយ

ឆ- មិនធ្លាប់ត្រូវបានផ្តន្ទាទោសពីបទឧក្រិដ្ឋ ឬបទមជ្ឈិមដោយចេតនា ដោយគ្មានការព្យួរទោស ឬផ្តន្ទាទោសជាបទវិន័យ ឬជាបទរដ្ឋបាល ដូចជា ការលុបឈ្មោះ ការបញ្ឈប់ពីមុខងារ ការហូតងារដោយមូលហេតុប្រព្រឹត្តអំពើផ្ទុយនឹងកិត្តិយស ឬអំពើមិនស្អាតស្អំ។

**ប្រការ៥ .-**

សមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលត្រូវបំពេញមុខងារដោយឯករាជ្យទាំងស្រុង និងនៅក្នុងវង្វង់នៃអំណាចរបស់ខ្លួន ដូចមានចែងក្នុងមាត្រា៣១២ នៃច្បាប់ស្តីពីការងារ។ គ្មានបុគ្គលណាម្នាក់ត្រូវផ្តល់ការណែនាំដល់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ឬដល់សមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលទាក់ទងនឹងការដោះស្រាយវិវាទការងារឡើយ។ សមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលត្រូវតែមានភាពមិនលំអៀង។

**ប្រការ៦ .-**

ក្រុមប្រឹក្សាអាជ្ញាកណ្តាលមានទីស្នាក់ការនៅរាជធានីភ្នំពេញ និងអាចមានការិយាល័យនៅតាមបណ្តាខេត្ត។

## ជំពូកទី ២
## សមាសភាពក្រុមអាជ្ញាកណ្តាល

**ប្រការ៧ .-**

វិវាទការងារទាំងឡាយដែលដាក់ជូនក្រុមប្រឹក្សាអាជ្ញាកណ្តាល ត្រូវដោះស្រាយដោយក្រុមអាជ្ញាកណ្តាលដែលត្រូវបង្កើតឡើងសម្រាប់តែការដោះស្រាយវិវាទការងារនោះ។ សេចក្តីបង្គាប់ដែលចេញដោយក្រុមអាជ្ញាកណ្តាល

ត្រូវចាត់ទុកជាសេចក្តីបង្គាប់របស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល។ ក្រុមអាជ្ញាកណ្តាលនីមួយៗ ត្រូវមានសមាជិក ៣ (បី) រូប ដែលជ្រើសចេញពីសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាល ដូចខាងក្រោម៖

ក- សមាជិក ១(មួយ)រូប មកពីសមាសភាពដូចមានចែងក្នុងប្រការ៣ ចំណុច ខ ខាងលើ ហើយត្រូវបានជ្រើសរើសដោយនិយោជក ដែលជាភាគីវិវាទ

ខ- សមាជិក ១(មួយ)រូប មកពីសមាសភាពដូចមានចែងក្នុងប្រការ៣ ចំណុច គ ខាងលើ ហើយត្រូវបានជ្រើសរើសដោយកម្មករនិយោជិត ឬសហជីព ឬក្រុមកម្មករនិយោជិតដែលជាភាគីវិវាទ

គ- សមាជិក ១(មួយ)រូប ដែលត្រូវធ្វើជាប្រធានក្រុមអាជ្ញាកណ្តាល និងដែលត្រូវបានជ្រើសរើសចេញពីសមាសភាពដូចមានចែងក្នុងប្រការ៣ ចំណុច ក ខាងលើ ដោយមានការឯកភាពពីសមាជិកទាំងពីរខាងលើ។ នៅក្នុងករណីដែលសមាជិកទាំងពីររូបនេះមិនឯកភាពគ្នាក្នុងការជ្រើសរើសប្រធានក្រុមអាជ្ញាកណ្តាល ការជ្រើសរើសនេះត្រូវរៀបចំដោយលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាលតាមការចាប់ឆ្នោតក្នុងចំណោមសមាសភាពដូចមានចែងក្នុងប្រការ៣ ចំណុច ក។

**ប្រការ៨ .-**

ក្នុងករណីដែលភាគីវិវាទមិនអាចឈានទៅដល់ការព្រមព្រៀងក្នុងការជ្រើសរើសអាជ្ញាកណ្តាលណាម្នាក់ លេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាលត្រូវរៀបចំជ្រើសរើសសមាជិកក្រុមអាជ្ញាកណ្តាលដោយការចាប់ឆ្នោត។

**ប្រការ៩ .-**

ក្នុងករណីដែលកម្មករនិយោជិតណាម្នាក់ត្រូវបានតម្រូវឱ្យចូលរួមក្នុងសវនាការរបស់ក្រុមអាជ្ញាកណ្តាលក្នុងម៉ោងធ្វើការ និយោជកត្រូវតែអនុញ្ញាតឱ្យកម្មករនិយោជិតនោះចូលរួមដោយមិនឱ្យប៉ះពាល់ដល់សិទ្ធិការងារទាំងឡាយរបស់កម្មករនិយោជិតនោះ។

**ប្រការ១០ .-**

សមាជិកម្នាក់ៗនៃក្រុមអាជ្ញាកណ្តាលត្រូវដកខ្លួនពីក្រុមអាជ្ញាកណ្តាល ដែលខ្លួនត្រូវបានគេជ្រើសរើស ប្រសិនមានមន្ទិលសង្ស័យអំពីភាពមិនលំអៀង ឬឯករាជ្យភាពរបស់ខ្លួន រួមមានទំនាក់ទំនងជិតស្និទ្ធជាលក្ខណៈបុគ្គល ឬអាជីពជាមួយភាគីណាមួយ ឬដោយមានផលប្រយោជន៍ផ្ទាល់ខ្លួន ឬផលប្រយោជន៍អាជីពផ្ទាល់ពីលទ្ធផលនៃសំណុំរឿងនោះ។

**ប្រការ១១ .-**

ការមិនបានដកខ្លួនពីសមាជិកក្រុមអាជ្ញាកណ្តាល ស្របតាមប្រការ១០ នៃប្រកាសនេះ អាចត្រូវបានយកធ្វើជាមូលហេតុនៃការមិនទទួលស្គាល់សេចក្តីបង្គាប់។

**ប្រការ១២ .-**

ក្នុងករណីដែលសមាជិកណាម្នាក់ក្នុងក្រុមអាជ្ញាកណ្តាលមិនអាចបំពេញមុខងាររបស់ខ្លួនបាន ដោយសារហេតុផលស្របច្បាប់ ឬដោយហេតុផលជាក់ស្តែងណាមួយ ត្រូវជ្រើសរើសអាជ្ញាកណ្តាលថ្មីមកជំនួសដោយផ្អែកតាមប្រការ៧ និងប្រការ៨ នៃប្រកាសនេះ។

## ជំពូកទី ៣
## ដំណើរការអាជ្ញាកណ្តាល

**ប្រការ១៣ .-**

ក្រុមអាជ្ញាកណ្តាលត្រូវអញ្ជើញភាគីវិវាទមកបកស្រាយបង្ហាញដោយផ្ទាល់មាត់នូវការអះអាងរបស់ខ្លួន នៅចំពោះមុខក្រុមអាជ្ញាកណ្តាល និងដាក់ជូននូវភស្តុតាង ឯកសារ និងព័ត៌មានចាំបាច់ផ្សេងៗទៀត។

**ប្រការ១៤ .-**

ភាគីវិវាទត្រូវបង្ហាញខ្លួននៅចំពោះមុខក្រុមអាជ្ញាកណ្តាលដោយអាចមានអ្នកអម ឬចាត់អ្នកតំណាងស្របច្បាប់ ដែលបានទទួលការប្រគល់សិទ្ធិជាលាយលក្ខណ៍អក្សរ។

**ប្រការ១៥ .-**

ក្នុងអំឡុងពេលនៃដំណើរការរបស់ក្រុមអាជ្ញាកណ្តាល ភាគីវិវាទត្រូវផ្អាករាល់វិធានការវិវាទ ដូចជា កូដកម្ម ឬឡុកអៅ ឬវិធានការដទៃទៀតដែលអាចធ្វើឱ្យស្ថានភាពវិវាទកាន់តែធ្ងន់ធ្ងរ។ ភាគីវិវាទត្រូវតែចូលរួមគ្រប់កិច្ចប្រជុំទាំងឡាយដែលក្រុមអាជ្ញាកណ្តាលបានអញ្ជើញឱ្យចូលរួម។

**ប្រការ១៦ .-**

ក្នុងករណីភាគីណាមួយបានទទួលការអញ្ជើញត្រឹមត្រូវ ប៉ុន្តែមិនបានមកបង្ហាញខ្លួននៅចំពោះមុខក្រុមអាជ្ញាកណ្តាលដោយគ្មានបង្ហាញមូលហេតុត្រឹមត្រូវ ក្រុមអាជ្ញាកណ្តាលអាចបន្ត ឬបញ្ចប់ដំណើរការអាជ្ញាកណ្តាលដោយចេញសេចក្តីបង្គាប់។

**ប្រការ១៧ .-**

ក្រុមអាជ្ញាកណ្តាលអាចដំណើរការប្រជុំ ឬសវនាការនៅទីស្នាក់ការកណ្តាល ឬការិយាល័យក្រុមប្រឹក្សាអាជ្ញាកណ្តាលតាមបណ្តាខេត្ត ឬកន្លែងផ្សេងទៀតនៅក្នុងព្រះរាជាណាចក្រកម្ពុជា សម្រាប់ពិគ្រោះយោបល់នៅក្នុងចំណោមសមាជិករបស់ខ្លួន ឬជួបភាគី សាក្សី ឬអ្នកជំនាញសម្រាប់ត្រួតពិនិត្យវត្ថុ ទ្រព្យសម្បត្តិដទៃទៀត ឬឯកសារ ឬការចុះពិនិត្យដល់ទីកន្លែងផ្ទាល់។ ក្រុមអាជ្ញាកណ្តាលត្រូវជូនដំណឹងដល់ភាគីពាក់ព័ន្ធអំពីទីកន្លែងដែលបានជ្រើសរើសសម្រាប់សកម្មភាពរបស់ខ្លួននេះ។

**ប្រការ១៨ .-**

ភាសាដែលត្រូវប្រើក្នុងដំណើរការរបស់ក្រុមអាជ្ញាកណ្តាល គឺភាសាខ្មែរ។ ភាគីណាមួយដែលមានបំណងនិយាយភាសាផ្សេងក្រៅពីភាសាខ្មែរទៅក្រុមអាជ្ញាកណ្តាល ឬមានសាក្សីដែលមិនចេះនិយាយភាសាខ្មែរ ភាគីនោះត្រូវនាំមកនូវអ្នកបកប្រែភាសាដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់ម្នាក់ចូលរួមក្នុងដំណើរការអាជ្ញាកណ្តាល។

**ប្រការ១៩ .-**

ក្រុមអាជ្ញាកណ្តាលមានអំណាចក្នុងការស៊ើបអំពីស្ថានភាពសេដ្ឋកិច្ចនៃសហគ្រាស និងស្ថានភាពសង្គមនៃកម្មករនិយោជិតដែលពាក់ព័ន្ធនៅក្នុងវិវាទ។ ក្រុមអាជ្ញាកណ្តាលនេះអាចអង្កេតគ្រប់យ៉ាងដែលមានការទាក់ទងនឹងសហគ្រាស ឬអង្គការវិជ្ជាជីវៈ ព្រមទាំងអាចតម្រូវឱ្យភាគីវិវាទប្រគល់ជូននូវឯកសារ ឬព័ត៌មានខាងសេដ្ឋកិច្ច គណនេយ្យ ស្ថិតិ ហិរញ្ញវត្ថុ ឬរដ្ឋបាលដែលអាចមានប្រយោជន៍ក្នុងការបំពេញបេសកកម្មរបស់ខ្លួន។ ក្រុមអាជ្ញាកណ្តាលនេះអាចស្នើសុំជំនួយពីអ្នកជំនាញបាន។

**ប្រការ២០ ._**

ក្រុមអាជ្ញាកណ្តាលត្រូវមានសេរីភាពក្នុងការកំណត់អំពីភាពដែលអាចទទួលយកបាន ភាពពាក់ព័ន្ធ ភាពសំខាន់ និងទម្ងន់នៃភស្តុតាង និងកំណត់ឱ្យភាគីណាមួយលើកភស្តុតាងមកបញ្ជាក់។

**ប្រការ២១ ._**

ក្រុមអាជ្ញាកណ្តាលមានអំណាចក្នុងការសាកសួរសាក្សី បើសិនជាយល់ឃើញថាសមស្រប។ ក្រុមអាជ្ញាកណ្តាលត្រូវកំណត់អំពីថ្ងៃ ពេលវេលា និងទីកន្លែងសម្រាប់សាកសួរសាក្សី។ ភាគីវិវាទទាំងអស់មានសិទ្ធិក្នុងការសាកសួរសាក្សីនៅចំពោះមុខក្រុមអាជ្ញាកណ្តាល។

**ប្រការ២២ ._**

គ្រប់សេចក្តីថ្លែង ឯកសារ ឬព័ត៌មានផ្សេងទៀតដែលប្រគល់ជូនក្រុមអាជ្ញាកណ្តាលដោយភាគីមួយត្រូវតែបញ្ជូនទៅភាគីមួយទៀត។ គ្រប់របាយការណ៍របស់អ្នកជំនាញ ឬឯកសារភស្តុតាងដែលក្រុមអាជ្ញាកណ្តាលយោងដើម្បីធ្វើសេចក្តីសម្រេច ត្រូវតែបញ្ជូនទៅភាគីវិវាទ។ ក្រុមអាជ្ញាកណ្តាលមានអំណាចក្នុងការចេញសេចក្តីសម្រេចសមស្រប ដើម្បីការពារដល់ការសម្ងាត់នៃព័ត៌មាននេះ។

**ប្រការ២៣ ._**

សមាជិកទាំងអស់នៃក្រុមអាជ្ញាកណ្តាលត្រូវតែរក្សាជាការសម្ងាត់នូវរាល់ព័ត៌មាន និងឯកសារដែលខ្លួនបានទទួល ព្រមទាំងអង្គហេតុណាមួយដែលខ្លួនបានដឹងក្នុងពេលបំពេញភារកិច្ច លើកលែងករណីដូចមានចែងក្នុងប្រការ២២ នៃប្រកាសនេះ។

**ប្រការ២៤ ._**

ការប្រជុំទាំងឡាយរវាងសមាជិកក្រុមអាជ្ញាកណ្តាលត្រូវធ្វើឡើងដោយសម្ងាត់។

**ប្រការ២៥ ._**

ក្រុមអាជ្ញាកណ្តាលអាចអញ្ជើញភាគីវិវាទទាំងអស់ជាលើកចុងក្រោយ ដើម្បីជួយឱ្យពួកគេឈានទៅដល់ដំណោះស្រាយមួយ។ ករណីនេះមិនអាចនាំឱ្យមានការពន្យារពេលហួសពីរយៈពេល១៥ (ដប់ប្រាំ) ថ្ងៃ នៃថ្ងៃធ្វើការបន្ទាប់ពីទទួលបានសំណុំរឿង លើកលែងតែភាគីទាំងពីរព្រមព្រៀងចំពោះការពន្យារពេលនោះ។ ការព្រមព្រៀងគ្នារវាងភាគីវិវាទក្នុងអំឡុងពេលនៃដំណើរការក្រុមអាជ្ញាកណ្តាលអាចធ្វើជាកម្មវត្ថុនៃសេចក្តីបង្គាប់អាជ្ញាកណ្តាលបាន។

**ប្រការ២៦ ._**

ដំណើរការអាជ្ញាកណ្តាលត្រូវអនុវត្តតាមវិធាននៃនីតិវិធីរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលដែលជាឧបសម្ព័ន្ធនៃប្រកាសនេះ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលអាចចេញសេចក្តីណែនាំ ដើម្បីសម្របសម្រួលដំណើរការអាជ្ញាកណ្តាល ដោយមិនត្រូវផ្ទុយនឹងច្បាប់ស្តីពីការងារ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។ សេចក្តីណែនាំត្រូវមានការយល់ព្រមពីសមាជិកទាំងអស់នៃក្រុមប្រឹក្សាអាជ្ញាកណ្តាល។ ប្រសិនបើសមាជិកទាំងអស់មិនមានការព្រមព្រៀងគ្នាទេ សេចក្តីណែនាំត្រូវធ្វើឡើងតាមមតិភាគច្រើនដាច់ខាតនៃសមាជិកទាំងអស់ក្នុងប្រភេទនីមួយៗនៃប្រភេទទាំងបីដែលមានចែងក្នុងប្រការ៣ នៃប្រកាសនេះ។

## ជំពូកទី ៤
## យុត្តាធិការ

**ប្រការ២៧ ._**

ក្រុមអាជ្ញាកណ្តាលត្រូវសម្រេចសេចក្តីលើវិវាទបុគ្គល និងវិវាទការងាររួមដែលដាក់មកខ្លួន បន្ទាប់ពីផ្សះផ្សាមិនបានសះជាដោយអធិការការងារ ឬអ្នកផ្សះផ្សា ស្របតាមមាត្រា៣០៩ នៃច្បាប់ស្តីពីការងារ។

**ប្រការ២៨ ._**

អំណាចរបស់ក្រុមអាជ្ញាកណ្តាលក្នុងការពិចារណាទៅលើវិវាទមួយ ត្រូវកម្រិតត្រឹមតែបញ្ហាទាំងឡាយណាដែលមានក្នុងកំណត់ហេតុនៃការផ្សះផ្សាមិនសះជា រួមទាំងបញ្ហាជាផលវិបាកផ្ទាល់នៃវិវាទនោះដែលកើតឡើងក្រោយការធ្វើកំណត់ហេតុ។

**ប្រការ២៩ ._**

ក្រុមអាជ្ញាកណ្តាលមានសិទ្ធិសម្រេចឱ្យភាគីវិវាទផ្តល់សំណង ចំពោះរាល់ការបំពានបទប្បញ្ញត្តិ ដែលមាននៅក្នុងច្បាប់ស្តីពីការងារ បទប្បញ្ញត្តិអនុវត្តច្បាប់ស្តីពីការងារ អនុសញ្ញារួម ឬក្នុងកាតព្វកិច្ចផ្សេងទៀតដែលកើតចេញពីទំនាក់ទំនងវិជ្ជាជីវៈរវាងនិយោជក និងកម្មករនិយោជិត។ ក្នុងដែនអនុវត្តនៃច្បាប់ស្តីពីការងារ និងប្រកាសនេះ ក្រុមអាជ្ញាកណ្តាលមានសិទ្ធិសម្រេច៖

ក- បញ្ជាឱ្យទទួលយកកម្មករនិយោជិតដែលបានបណ្តេញចេញឱ្យចូលមកធ្វើការវិញនៅក្នុងតំណែងចាស់ ឬតំណែងសមរម្យណាមួយ

ខ- បញ្ជាឱ្យបង់ប្រាក់ជាបន្ទាន់នូវប្រាក់ដែលត្រូវបង់

គ- បញ្ជាឱ្យបញ្ឈប់ជាបន្ទាន់នូវកូដកម្ម ឬឡុកអៅ ដែលកំពុងធ្វើឡើងដោយភាគីវិវាទ

ឃ-បញ្ជាឱ្យបញ្ឈប់ជាបន្ទាន់នូវរាល់ការប្រព្រឹត្តទាំងឡាយណា ដែលមិនស្របច្បាប់ ឬដែលត្រូវហាមឃាត់

ង- បញ្ជាឱ្យធ្វើការចរចាដើម្បីស្វែងរកដំណោះស្រាយណាមួយ

ច- បញ្ជាឱ្យអនុវត្តតាមដំណោះស្រាយក្រោមប្រការ២៥ នៃប្រកាសនេះ

ឆ- បង្កើតលក្ខខណ្ឌទាំងឡាយសម្រាប់អនុសញ្ញារួម

ជ- សងការខូចខាតផ្សេងៗទៀតតាមការសមស្រប។

**ប្រការ៣០ ._**

ក្រុមប្រឹក្សាអាជ្ញាកណ្តាលអាចជូនដំណឹងអំពីសេចក្តីបង្គាប់ទៅអធិការការងារ ដើម្បីជួយចាត់វិធានការតាមដានការអនុវត្តសេចក្តីបង្គាប់នោះ។

## ជំពូកទី ៥
## សេចក្តីបង្គាប់អាជ្ញាកណ្តាល

**ប្រការ៣១ ._**

ក្រុមអាជ្ញាកណ្តាលត្រូវព្យាយាមឱ្យបានសំឡេងឯកច្ឆន្ទក្នុងការសម្រេចសេចក្តីរបស់ខ្លួន។ ប្រសិនបើសំឡេងឯកច្ឆន្ទមិនអាចរកបានទេ ក្រុមអាជ្ញាកណ្តាលត្រូវធ្វើសេចក្តីសម្រេចរបស់ខ្លួនតាមសំឡេងភាគច្រើន។

**ប្រការ៣២ .-**

ក្រុមអាជ្ញាកណ្តាលត្រូវកត់ត្រារាល់ការសម្រេចក្នុងសេចក្តីបង្គាប់ដែលត្រូវចុះហត្ថលេខាដោយអាជ្ញាកណ្តាលទាំង ៣(បី)រូប។ ក្នុងករណីដែលអាជ្ញាកណ្តាលណាម្នាក់មិនឯកភាពនឹងការសម្រេចតាមមតិភាគច្រើន អាជ្ញាកណ្តាលអាចកត់ត្រាយោបល់ជំទាស់ជាឧបសម្ព័ន្ធនៃសេចក្តីបង្គាប់។

**ប្រការ៣៣ .-**

សេចក្តីបង្គាប់អាជ្ញាកណ្តាលមាន ២(ពីរ)ប្រភេទ គឺសេចក្តីបង្គាប់ជាប់កាតព្វកិច្ច និងសេចក្តីបង្គាប់មិនជាប់កាតព្វកិច្ច។

សេចក្តីបង្គាប់អាជ្ញាកណ្តាលត្រូវចែងអំពី៖

ក- កាលបរិច្ឆេទនៃសេចក្តីបង្គាប់

ខ- ឈ្មោះរបស់អាជ្ញាកណ្តាលទាំង ៣(បី)រូប

គ- ឈ្មោះ អាសយដ្ឋាន និងទីកន្លែងធ្វើការ ឬកន្លែងស្នាក់នៅពិតប្រាកដរបស់ភាគី

ឃ-សេចក្តីសង្ខេបស្តីពីនីតិវិធី

ង- សេចក្តីពិពណ៌នាអំពីបណ្តឹង និងបណ្តឹងតប ប្រសិនជាមាន

ច- ហេតុផលនៃការសម្រេចដែលចែងនៅក្នុងសេចក្តីបង្គាប់ ព្រមទាំងសេចក្តីយោងទៅនឹងបញ្ញត្តិពាក់ព័ន្ធទាំងឡាយ ដែលមានចែងក្នុងច្បាប់ស្តីពីការងារ ច្បាប់ស្តីពីសហជីព បទប្បញ្ញត្តិសម្រាប់អនុវត្តច្បាប់ស្តីពីការងារ ឬអនុសញ្ញារួម ឬកិច្ចសន្យាការងារនីមួយៗ បើសិនជាមាន

ឆ- រាល់ការសម្រេចរបស់ក្រុមអាជ្ញាកណ្តាល។

**ប្រការ៣៤ .-**

ក្នុងរយៈពេល ១៥(ដប់ប្រាំ)ថ្ងៃ នៃថ្ងៃធ្វើការ ចាប់ពីថ្ងៃដែលខ្លួនបានទទួលសំណុំរឿង ក្រុមប្រឹក្សាអាជ្ញាកណ្តាលត្រូវរាយការណ៍អំពីសេចក្តីបង្គាប់របស់ខ្លួនជាលាយលក្ខណ៍អក្សរជូនទៅរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីចាត់ការផ្តល់ដំណឹងទៅភាគីវិវាទភ្លាមអំពីសេចក្តីបង្គាប់នោះ ដោយផ្តល់ជូនភាគីទាំងនោះនូវសេចក្តីចម្លងសេចក្តីបង្គាប់ ដែលបានបញ្ជាក់ថាត្រឹមត្រូវចំនួន ១(មួយ)ច្បាប់ម្នាក់។ ក្នុងករណីដែលដំណើរការសំណុំរឿងត្រូវបានបញ្ចប់ ដោយមិនមានសេចក្តីបង្គាប់នោះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលត្រូវជូនដំណឹងទៅរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ អំពីការបញ្ចប់នៃដំណើរការនេះ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលត្រូវចេញសេចក្តីសម្រេចបិទបញ្ចប់សំណុំរឿងដោយមិនចេញសេចក្តីបង្គាប់ ក្នុងករណីដើមចោទបានដកពាក្យបណ្តឹង ឬមានកិច្ចព្រមព្រៀងសះជារបស់ភាគីវិវាទ ឬការដំណើរការអាជ្ញាកណ្តាលមិនអាចបន្តទៀតកើត និងត្រូវជូនដំណឹងទៅរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ អំពីការបញ្ចប់ដំណើរការអាជ្ញាកណ្តាល។

**ប្រការ៣៥ .-**

សេចក្តីបង្គាប់អាជ្ញាកណ្តាលដែលជាសេចក្តីបង្គាប់ជាប់កាតព្វកិច្ច ត្រូវចូលជាស្ថាពរ ហើយភាគីវិវាទមានកាតព្វកិច្ចអនុវត្តភ្លាម។

**ប្រការ៣៦ ._**

ភាគីវិវាទនីមួយៗអាចជំទាស់ទៅនឹងសេចក្តីបង្គាប់អាជ្ញាកណ្តាល ដែលជាសេចក្តីបង្គាប់មិនជាប់កាតព្វកិច្ច ដោយជូនព័ត៌មានទៅរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តាមសំបុត្រអនុសិដ្ឋ ឬតាមមធ្យោបាយដែលទុកជាបានការ ក្នុងរយៈពេល ៨(ប្រាំបី)ថ្ងៃប្រតិទិន បន្ទាប់ពីបានទទួលដំណឹងអំពីសេចក្តីបង្គាប់។ ប្រសិនបើថ្ងៃចុងក្រោយនៃរយៈពេលនេះមិនមែនជាថ្ងៃធ្វើការសម្រាប់មន្ត្រីរាជការស៊ីវិល រយៈពេលនេះត្រូវពន្យារបន្ថែមទៅថ្ងៃធ្វើការបន្ទាប់។

ប្រសិនបើភាគីណាមួយនៃវិវាទបានដាក់ពាក្យជំទាស់ក្នុងអំឡុងពេលនេះ សេចក្តីបង្គាប់នោះមិនអាចអនុវត្តបានឡើយ។ ក្នុងករណីនេះ បើវិវាទជាវិវាទអំពីសិទ្ធិ ភាគីវិវាទអាចប្តឹងអំពីករណីនេះទៅតុលាការមានសមត្ថកិច្ចសម្រាប់ការដោះស្រាយចុងក្រោយ។

**ប្រការ៣៧ ._**

សេចក្តីបង្គាប់អាជ្ញាកណ្តាលដែលជាសេចក្តីបង្គាប់មិនជាប់កាតព្វកិច្ចនឹងត្រូវចូលជាស្ថាពរ ហើយភាគីវិវាទមានកាតព្វកិច្ចត្រូវអនុវត្តតាម ប្រសិនបើមិនមានភាគីវិវាទណាមួយដាក់ពាក្យជំទាស់ក្នុងរយៈពេលដែលបានកំណត់ក្នុងប្រការ៣៦ នៃប្រកាសនេះ។

**ប្រការ៣៨ ._**

ប្រការ៣៦ នៃប្រកាសនេះ មិនអាចយកមកអនុវត្តបានទេ ក្នុងករណីដែលភាគីទាំងឡាយនៃវិវាទបានឯកភាពគ្នាជាលាយលក្ខណ៍អក្សរមុនពេលជូនដំណឹងអំពីសេចក្តីបង្គាប់អាជ្ញាកណ្តាល ឬក្នុងករណីដែលភាគីវិវាទបានជាប់កាតព្វកិច្ចអនុវត្តតាមអនុសញ្ញារួម ដែលចែងអំពីការមិនជំទាស់ទៅនឹងសេចក្តីបង្គាប់អាជ្ញាកណ្តាលណាមួយ។ ក្នុងករណីនេះ សេចក្តីបង្គាប់អាជ្ញាកណ្តាលត្រូវក្លាយជាស្ថាពរ ហើយត្រូវយកមកអនុវត្តភ្លាមបន្ទាប់ពីការជូនដំណឹង។

## ជំពូកទី ៦
## សេចក្តីបង្គាប់ទាក់ទងនឹងវិវាទផលប្រយោជន៍

**ប្រការ៣៩ ._**

សេចក្តីបង្គាប់អាជ្ញាកណ្តាលដែលដោះស្រាយវិវាទផលប្រយោជន៍នឹងមកជំនួសអនុសញ្ញារួម និងមានប្រសិទ្ធភាពអនុវត្តរយៈពេល ៣(បី)ឆ្នាំ ចាប់ពីថ្ងៃចូលជាស្ថាពរ លើកលែងតែភាគីវិវាទបានព្រមព្រៀងគ្នាលើការធ្វើអនុសញ្ញារួមថ្មី ដើម្បីដាក់ជំនួសសេចក្តីបង្គាប់នោះ។

សេចក្តីបង្គាប់ដែលចូលជាស្ថាពរនេះត្រូវរក្សាទុក និងចុះបញ្ជីស្របតាមនីតិវិធីនៃការចុះបញ្ជីអនុសញ្ញារួមដើម្បីមានអានុភាពអនុវត្តដូចអនុសញ្ញារួម។

## ជំពូកទី ៧
## ការអនុវត្ត

**ប្រការ៤០ ._**

ក្នុងករណីភាគីណាមួយមិនអនុវត្តតាមសេចក្តីបង្គាប់ស្ថាពរ ភាគីម្ខាងទៀតអាចដាក់ពាក្យសុំចេញដីកាសម្រេចអនុវត្តសេចក្តីបង្គាប់អាជ្ញាកណ្តាលទៅតុលាការមានសមត្ថកិច្ច។

**ប្រការ៤១ ._**

សេចក្ដីបង្គាប់អាជ្ញាកណ្ដាលស្ថាពរអាចត្រូវបានតុលាការបដិសេធ ប្រសិនបើភាគីលើកសំអាងពីភាពមិនត្រឹមត្រូវនៃសេចក្ដីបង្គាប់ដូចខាងក្រោម៖

ក- ភាគីវិវាទមិនបានចូលរួមត្រឹមត្រូវក្នុងការជ្រើសរើសអាជ្ញាកណ្ដាល ឬមិនបានទទួលនូវការជូនដំណឹងត្រឹមត្រូវអំពីដំណើរការអាជ្ញាកណ្ដាល ឬត្រូវបានរារាំងយ៉ាងអយុត្តិធម៌មិនឱ្យធ្វើការបកស្រាយឱ្យបានក្បោះក្បាយអំពីរឿងក្ដីរបស់ខ្លួន។

ខ- ការមិនអនុវត្តតាមនីតិវិធីនៃការចេញសេចក្ដីបង្គាប់ដូចមានចែងក្នុងច្បាប់ស្ដីពីការងារ។

គ- ក្រុមប្រឹក្សាអាជ្ញាកណ្ដាលបានចេញសេចក្ដីបង្គាប់ ដែលហួសពីអំណាចដែលច្បាប់ស្ដីពីការងារប្រគល់ឱ្យ។

## ជំពូកទី ៨
## លេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្ដាល

**ប្រការ៤២ ._**

ក្រុមប្រឹក្សាអាជ្ញាកណ្ដាលមានលេខាធិការដ្ឋានដើម្បីគ្រប់គ្រង និងសម្របសម្រួលដល់ការដោះស្រាយវិវាទការងារដោយក្រុមប្រឹក្សាអាជ្ញាកណ្ដាល។

ការរៀបចំ និងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្ដាល ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងការងារនិងបណ្ដុះបណ្ដាលវិជ្ជាជីវៈ។

## ជំពូកទី ៩
## ប្រភពហិរញ្ញវត្ថុរបស់ក្រុមប្រឹក្សាអាជ្ញាកណ្ដាល

**ប្រការ៤៣ ._**

ហិរញ្ញវត្ថុរបស់ក្រុមប្រឹក្សាអាជ្ញាកណ្ដាលមានប្រភពមកពី៖

- ថវិកាជាតិ
- ម្ចាស់ជំនួយ
- អំណោយ ឬអច្ច័យទានផ្សេងៗ
- ប្រភពស្របច្បាប់ដទៃផ្សេងទៀត។

## ជំពូកទី ១០
## អន្តរប្បញ្ញត្តិ

**ប្រការ៤៤ ._**

ក្រុមអាជ្ញាកណ្ដាលទទួលដោះស្រាយវិវាទបុគ្គល ដែលជាវិវាទអំពីសិទ្ធិពាក់ព័ន្ធនឹងបុគ្គលដែលទទួលបានការការពារជាពិសេសក្រោមបទប្បញ្ញត្តិច្បាប់ស្ដីពីសហជីព ជាដំណាក់កាលដំបូង។

ការដោះស្រាយវិវាទបុគ្គលផ្សេងទៀតដោយក្រុមអាជ្ញាកណ្ដាល ត្រូវកំណត់ដោយសេចក្ដីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ។

**ប្រការ៤៥ .-**

អាជ្ញាកណ្តាលដែលត្រូវបានតែងតាំងមុនប្រកាសនេះចូលជាធរមាន ត្រូវទទួលបានងារជាអាជ្ញាកណ្តាលកិត្តិយស លើកលែងតែបានបំពេញគ្រប់គុណវុឌ្ឍិដូចកំណត់ក្នុងប្រកាសនេះ។ អាជ្ញាកណ្តាលកិត្តិយសមិនទទួលដោះស្រាយសំណុំរឿង។

## ជំពូកទី ១១

## អវសានប្បញ្ញត្តិ

**ប្រការ៤៦ .-**

ប្រកាសលេខ០៩៩ សកបយ. ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៤៧ .-**

អគ្គលេខាធិការ អគ្គនាយកនៃអគ្គនាយកដ្ឋានទំនាក់ទំនងវិជ្ជាជីវៈនិងដោះស្រាយវិវាទការងារក្រៅប្រព័ន្ធតុលាការ អគ្គនាយកនៃអគ្គនាយកដ្ឋានអធិការកិច្ចការងារ អគ្គនាយកនៃអគ្គនាយកដ្ឋានការងារ ប្រធានគ្រប់អង្គភាពពាក់ព័ន្ធ និងប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី ខេត្ត ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ ចន្ទ ១១កើត ខែ ចេត្រ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៣ ខែមេសា ឆ្នាំ២០២៦

**រដ្ឋមន្ត្រី**

**ហេង សួរ**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលរាជធានី ខេត្ត
- ដូចប្រការ៤៧
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធនៃប្រកាសលេខ០៩៨/២៦ ក.ប/ប្រ.ក.ទ.ក ចុះថ្ងៃទី១៣ ខែមេសា ឆ្នាំ២០២៦ ស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល

# វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល

## វិធានទី១៖ លេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល

១.១ លេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាលមានអាសយដ្ឋានស្ថិតនៅអគារស្នាក់ការកណ្តាលបេឡាជាតិសន្តិសុខសង្គម (ប.ស.ស.) នៃក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ (ជាន់ទី១៨) ភូមិសំរោង សង្កាត់ឃ្មួញ ខណ្ឌសែនសុខ រាជធានីភ្នំពេញ។
ការផ្លាស់ប្តូរអាសយដ្ឋាននៃលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលត្រូវជូនដំណឹងជាសាធារណៈ។

១.២ ភាគីវិវាទត្រូវសហការជាមួយលេខាធិការដ្ឋាន ដើម្បីដោះស្រាយវិវាទការងារឱ្យបានឆាប់រហ័ស និងប្រកបដោយប្រសិទ្ធភាព។

១.៣ រាល់ការប្រាស្រ័យទាក់ទងគ្នារវាងក្រុមអាជ្ញាកណ្តាលនិងភាគីវិវាទក្រៅពីពេលសវនាការ ត្រូវធ្វើតាមរយៈលេខាធិការដ្ឋាន។

១.៤ លេខាធិការដ្ឋានត្រូវមានវត្តមានក្នុងការជួយភាគី ដែលមានសំណួរពាក់ព័ន្ធនឹងទិដ្ឋភាពនៃនីតិវិធីដោះស្រាយវិវាទ និងជួយក្នុងការបំភ្លឺបញ្ហាដែលកើតចេញពីប្រកាស ឬពីវិធាននៃនីតិវិធីនេះ។

## វិធានទី២៖ ការជ្រើសរើសអាជ្ញាកណ្តាល

២.១ លេខាធិការដ្ឋានត្រូវប្រើគ្រប់វិធានការដើម្បីសម្របសម្រួលបង្កើតជាក្រុមអាជ្ញាកណ្តាលមួយ ក្នុងរយៈពេល ៣ (បី) ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីបានទទួលរបាយការណ៍ផ្សះផ្សាមិនសះជា និងបានចុះលេខរៀងសំណុំរឿង។

២.២ ក្នុងការជួយដល់ដំណើរការជ្រើសរើសអាជ្ញាកណ្តាល លេខាធិការដ្ឋានត្រូវ៖

ក- ផ្តល់ឱ្យនិយោជក ដែលជាភាគីវិវាទនូវបញ្ជីនៃអាជ្ញាកណ្តាលដែលត្រូវស្នើឈ្មោះឡើងដោយអង្គការវិជ្ជាជីវៈរបស់និយោជក។

ខ- ផ្តល់ឱ្យកម្មករនិយោជិត ឬក្រុមកម្មករនិយោជិត ឬអង្គការវិជ្ជាជីវៈរបស់កម្មករនិយោជិតដែលជាភាគីវិវាទនូវបញ្ជីនៃអាជ្ញាកណ្តាល ដែលត្រូវស្នើឈ្មោះឡើងដោយអង្គការវិជ្ជាជីវៈរបស់កម្មករនិយោជិត។

គ- ការជ្រើសរើសអាជ្ញាកណ្តាលដោយការចាប់ឆ្នោតនៅថ្ងៃទីបី បន្ទាប់ពីទទួលបានរបាយការណ៍ផ្សះផ្សាមិនសះជាក្នុងករណីភាគីវិវាទមិនអាចជ្រើសរើសអាជ្ញាកណ្តាល។

២.៣ បន្ទាប់ពីភាគីវិវាទបានជ្រើសរើសអាជ្ញាកណ្តាលរួច លេខាធិការដ្ឋានត្រូវសួរបញ្ជាក់អាជ្ញាកណ្តាល ដែលត្រូវបានជ្រើសរើសអំពីការព្រមទទួលយកសំណុំរឿង។ អាជ្ញាកណ្តាលដែលមិនអាចទទួលយកសំណុំរឿងបានត្រូវជូនដំណឹងទៅលេខាធិការដ្ឋាន ដោយបញ្ជាក់អំពីមូលហេតុ ជាអាទិ៍ ទំនាស់ផលប្រយោជន៍ ឬធុរៈ ឬកត្តាសុខភាព។

២.៤ នៅពេលអាជ្ញាកណ្តាលណាមួយដែលត្រូវបានជ្រើសរើសមិនអាចបំពេញមុខងារក្នុងក្រុមអាជ្ញាកណ្តាលបាន លេខាធិការដ្ឋានត្រូវឱ្យភាគី ដែលបានជ្រើសរើសអាជ្ញាកណ្តាលនោះ ធ្វើការជ្រើសរើសអាជ្ញាកណ្តាលផ្សេងទៀត។

២.៥ អាជ្ញាកណ្តាលទាំងពីរ ដែលត្រូវបានជ្រើសរើសរួចហើយត្រូវពិភាក្សាគ្នាដើម្បីជ្រើសរើសអាជ្ញាកណ្តាលមួយរូបទៀតចេញពីបញ្ជីអាជ្ញាកណ្តាល ដែលស្នើឡើងដោយក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីធ្វើជាប្រធានក្រុមអាជ្ញាកណ្តាល។

២.៦ ប្រសិនបើអាជ្ញាកណ្តាលទាំងពីរឯកភាពគ្នាលើការជ្រើសរើសប្រធានក្រុមអាជ្ញាកណ្តាល លេខាធិការដ្ឋានត្រូវសួរបញ្ជាក់អាជ្ញាកណ្តាលដែលត្រូវបានជ្រើសរើសអំពីការព្រមទទួលយកសំណុំរឿង។
លេខាធិការដ្ឋានត្រូវជូនដំណឹងទៅប្រធានក្រុមអាជ្ញាកណ្តាលអំពីលេខរៀងសំណុំរឿងនិងភាគីវិវាទ។
ប្រធានក្រុមអាជ្ញាកណ្តាល ដែលមិនអាចទទួលយកសំណុំរឿងបានត្រូវជូនដំណឹងទៅលេខាធិការដ្ឋានដោយបញ្ជាក់អំពីមូលហេតុ ជាអាទិ៍ ទំនាស់ផលប្រយោជន៍ ឬធុរៈ ឬកត្តាសុខភាព។

២.៧ ប្រសិនបើអាជ្ញាកណ្តាលទាំងពីរមិនឯកភាពគ្នាលើការជ្រើសរើសប្រធានក្រុមអាជ្ញាកណ្តាល លេខាធិការដ្ឋានត្រូវជ្រើសរើសប្រធានក្រុមអាជ្ញាកណ្តាល ដោយការចាប់ឆ្នោត និងសួរបញ្ជាក់អំពីភាពអាចធ្វើជាប្រធានក្រុមអាជ្ញាកណ្តាលបាន។

២.៨ នីតិវិធីចាប់ឆ្នោតជ្រើសរើសអាជ្ញាកណ្តាល ត្រូវអនុវត្តដូចខាងក្រោម៖

ក- មន្ត្រីនៃលេខាធិការដ្ឋានម្នាក់ដែលត្រូវបានចាត់តាំងឡើង ត្រូវសរសេរលើក្រដាសសន្លឹកផ្សេងៗគ្នានូវឈ្មោះរបស់អាជ្ញាកណ្តាលនីមួយៗពីបញ្ជីឈ្មោះសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលដែលត្រូវជ្រើសរើស និងត្រូវប្រមូលក្រដាសទាំងនេះ ដាក់ក្នុងប្រអប់ស្រអាប់មួយ ដើម្បីជ្រើសរើសដោយព្រាវនូវក្រដាសមួយសន្លឹក ដែលមានឈ្មោះអាជ្ញាកណ្តាលម្នាក់។

ខ- ភាគីវិវាទនិងអាជ្ញាកណ្តាលណាមួយ ដែលត្រូវបានគេជ្រើសរើសឱ្យធ្វើជាសមាជិកក្រុមអាជ្ញាកណ្តាល នឹងទទួលបាននូវសេចក្តីជូនដំណឹងអំពីការប្រព្រឹត្តទៅនៃនីតិវិធីចាប់ឆ្នោត និងអាចចូលរួមនីតិវិធីចាប់ឆ្នោត។

២.៩ ក្រុមអាជ្ញាកណ្តាលត្រូវបានចាត់ទុកថាបានបង្កើតឡើងនៅពេលដែលអាជ្ញាកណ្តាលទាំងបី ត្រូវបានជ្រើសរើសរួច។

២.១០ ប្រសិនបើសមាជិកក្រុមអាជ្ញាកណ្តាលណាម្នាក់មិនអាចបំពេញមុខងារបាន ដោយសារមូលហេតុណាមួយ លេខាធិការដ្ឋានត្រូវជ្រើសរើសអាជ្ញាកណ្តាលថ្មីមកជំនួស ស្របតាមនីតិវិធីដែលកំណត់ក្នុងវិធាននេះ។

## វិធានទី៣៖ ដំណើរការអាជ្ញាកណ្តាល

៣.១ ក្រុមអាជ្ញាកណ្តាលត្រូវប្រជុំដោយផ្ទាល់ ឬតាមទូរសព្ទ ឬប្រព័ន្ធទំនាក់ទំនងអេឡិចត្រូនិចនានា ក្នុងរយៈពេល ៣ (បី) ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីក្រុមអាជ្ញាកណ្តាលត្រូវបានបង្កើតឡើង។ ក្រុមអាជ្ញាកណ្តាលត្រូវជូនដំណឹង

ទៅលេខាធិការដ្ឋានអំពីការប្រជុំនេះ និងអំពីសេចក្តីសម្រេចផ្សេងៗ ដែលបានធ្វើក្នុងពេលប្រជុំ។ បន្ទាប់ពីបានទទួលការណែនាំពីក្រុមអាជ្ញាកណ្តាល លេខាធិការដ្ឋានត្រូវជូនដំណឹងទៅភាគីអំពីកាលបរិច្ឆេទ និងទីកន្លែង ដែលភាគីត្រូវមកបង្ហាញខ្លួននៅចំពោះមុខក្រុមអាជ្ញាកណ្តាល។

៣.២ ក្រុមអាជ្ញាកណ្តាលអាចតម្រូវឱ្យភាគីវិវាទបញ្ជាក់អំពីការទាមទារ និងចម្លើយជាលាយលក្ខណ៍អក្សរបន្ថែមលើការបកស្រាយបង្ហាញដោយផ្ទាល់មាត់នូវការអះអាងរបស់ភាគីវិវាទក្នុងសវនាការ។

៣.៣ ក្រុមអាជ្ញាកណ្តាលមានសិទ្ធិសម្រេចលើការរៀបចំចំណុចវិវាទសម្រាប់ការជំនុំជម្រះ។

៣.៤ ប្រធានក្រុមអាជ្ញាកណ្តាលត្រូវចម្លងទុកនូវរាល់សេចក្តីណែនាំ ការជូនដំណឹង យោបល់ ឬការប្រាស្រ័យទាក់ទងដែលមានលក្ខណៈប្រហាក់ប្រហែល ដែលធ្វើឡើងដោយក្រុមអាជ្ញាកណ្តាល ក្នុងពេលជំនុំជម្រះ ហើយត្រូវផ្តល់ឱ្យលេខាធិការដ្ឋាននូវឯកសារទាំងនេះចំនួន១ (មួយ) ច្បាប់ ។

៣.៥ ក្រុមអាជ្ញាកណ្តាលអាចតម្រូវឱ្យភាគីវិវាទផ្តល់ភស្តុតាងជាឯកសារ ឬសាក្សី ដែលមានប្រយោជន៍ក្នុងការសម្រេចសេចក្តី និងអញ្ជើញអ្នកជំនាញមកជួយទៀតផង។

៣.៦ ភាគីវិវាទមានសិទ្ធិពិនិត្យភស្តុតាងណាមួយ ដែលបានបង្ហាញដល់ក្រុមអាជ្ញាកណ្តាល និងចោទសួរសាក្សី។

៣.៧ ប្រសិនបើភាគីវិវាទ ឬអ្នកតំណាងស្របច្បាប់របស់ភាគីវិវាទអវត្តមាន ក្នុងដំណើរការអាជ្ញាកណ្តាល បន្ទាប់ពីបានទទួលការជូនដំណឹងយ៉ាងត្រឹមត្រូវអំពីកាលបរិច្ឆេទ ពេលវេលា និងទីកន្លែងនៃដំណើរការអាជ្ញាកណ្តាល ក្រុមអាជ្ញាកណ្តាលអាចបន្តដំណើរការ ឬអាចបញ្ចប់ដំណើរការអាជ្ញាកណ្តាល ដោយចេញជាសេចក្តីបង្គាប់។

៣.៨ ក្នុងការធ្វើសេចក្តីសម្រេចទាក់ទងនឹងដំណើរការ រួមទាំងការមិនឯកភាពគ្នារបស់ភាគីវិវាទអំពីដំណើរការនីតិវិធី ក្រុមអាជ្ញាកណ្តាលត្រូវផ្អែកលើការពិចារណាលើភាពយុត្តិធម៌ ដំណោះស្រាយវិវាទឱ្យបានឆាប់រហ័ស និងប្រកបដោយប្រសិទ្ធភាព។

៣.៩ ក្រុមអាជ្ញាកណ្តាលគួរចៀសវាងការលើកពេលសវនាការ ឬអាចកំណត់ធ្វើសវនាការបន្តទៅថ្ងៃក្រោយទៀតបាន លើកលែងតែមានការឯកភាពគ្នារវាងភាគីវិវាទ។

៣.១០ បន្ទាប់ពីការផ្សះផ្សាមិនសះជានៅចំពោះមុខអធិការការងារ ឬអ្នកផ្សះផ្សា ភាគីវិវាទអាចបន្តផ្សះផ្សា ដើម្បីដោះស្រាយវិវាទ ទោះបីជាក្នុងដំណើរការអាជ្ញាកណ្តាលក៏ដោយ។

៣.១១ ក្រុមអាជ្ញាកណ្តាលតាមរយៈលេខាធិការដ្ឋានត្រូវតម្កល់ទុកនូវភស្តុតាង និងសេចក្តីបង្គាប់អាជ្ញាកណ្តាល ឬសេចក្តីសម្រេចរបស់ខ្លួន។

## **ជំពូកទី៤៖ សេចក្តីបង្គាប់/សេចក្តីសម្រេច**

៤.១ ក្រុមអាជ្ញាកណ្តាលត្រូវជូនដំណឹងទៅលេខាធិការដ្ឋានអំពីសេចក្តីបង្គាប់ ឬសេចក្តីសម្រេចរបស់ខ្លួនក្នុងរយៈពេល១៥ (ដប់ប្រាំ) ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីក្រុមអាជ្ញាកណ្តាលត្រូវបានបង្កើតឡើង លើកលែងតែភាគីបានព្រមព្រៀងគ្នាផ្សេងពីនេះ។ ក្រុមអាជ្ញាកណ្តាលត្រូវចេញសេចក្តីសម្រេចបិទបញ្ចប់សំណុំរឿង

ដោយមិនចេញសេចក្តីបង្គាប់ ក្នុងករណីដើមចោទបានដកពាក្យបណ្តឹង ឬមានកិច្ចព្រមព្រៀងសះជារបស់ភាគីវិវាទ ឬការដំណើរការអាជ្ញាកណ្តាលមិនអាចបន្តទៀតកើត និងត្រូវជូនដំណឹងទៅលេខាធិការដ្ឋានអំពីការបញ្ចប់ដំណើរការអាជ្ញាកណ្តាល។

៤.២ ក្រុមអាជ្ញាកណ្តាលត្រូវចេញសេចក្តីបង្គាប់ជាលាយលក្ខណ៍អក្សរតាមទម្រង់គំរូ និងត្រូវផ្តល់ឱ្យលេខាធិការដ្ឋានដើម្បីចាត់ការបន្ត។

៤.៣ បន្ទាប់ពីបានទទួលសេចក្តីបង្គាប់ ឬសេចក្តីសម្រេច លេខាធិការដ្ឋានត្រូវចាត់ការផ្តល់ដំណឹងទៅភាគីវិវាទភ្លាមអំពីសេចក្តីបង្គាប់ ឬសេចក្តីសម្រេចនោះ ដោយផ្តល់ជូនភាគីវិវាទនូវសេចក្តីចម្លងដែលបានបញ្ជាក់ថាត្រឹមត្រូវចំនួន១ (មួយ) ច្បាប់ម្នាក់ (ភាគីអាចសុំចម្លងបន្ថែមបានតាមតម្រូវការជាក់លាក់ ដោយឥតគិតថ្លៃ)។ ការជូនដំណឹងអាចធ្វើឡើងតាមការបញ្ជូនសេចក្តីបង្គាប់ទៅភាគី ទៅអាសយដ្ឋានរបស់ភាគីវិវាទ ឬរបស់អ្នកតំណាងស្របច្បាប់របស់ភាគីវិវាទ ដែលបានផ្តល់ព័ត៌មានឱ្យលេខាធិការដ្ឋាន ឬតាមរយៈមធ្យោបាយអេឡិចត្រូនិចដែលចាត់ទុកថាបានការ។